**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តរតនគិរី**
**គណៈកម្មាធិការលទ្ធកម្មខេត្ត**
លេខ : ០១២/១៨ ស.ជ.ណ

ថ្ងៃ អង្គារ ១២ រោច ខែ កត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២
ធ្វើនៅខេត្តរតនគិរី ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១៨

## សេចក្ដីជូនដំណឹង

## ស្ដីពី

## ការអញ្ជើញចូលរួមដេញថ្លៃការសាងសង់អគារច្រកចេញចូលតែមួយជាន់ផ្ទាល់ដីនៅស្រុកបរកែវ ទំហំ ២២០ម៉ែត្រការ៉េ ប្រចាំឆ្នាំ២០១៨ ជូនរដ្ឋបាលខេត្តរតនគិរី

រដ្ឋបាលខេត្តរតនគិរី សូមជូនដំណឹងដល់បណ្ដាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល)ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា រដ្ឋបាលខេត្តរតនគិរី នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការសាងសង់អគារច្រកចេញចូលតែមួយជាន់ផ្ទាល់ដីនៅស្រុកបរកែវ ទំហំ ២២០ម៉ែត្រការ៉េ ប្រចាំឆ្នាំ២០១៨ ជូនរដ្ឋបាលខេត្តរតនគិរី ។

រដ្ឋបាលខេត្តរតនគិរី បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មខេត្តរតនគិរី ដែលមានអាសយដ្ឋានភូមិទេសអន្លង់ សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតនគិរី ចាប់ពីថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ២០១៨ តទៅ រៀងរាល់ម៉ោងធ្វើការ ( ទូរស័ព្ទទាក់ទងលេខ ០៦១ ៣៣ ៧៧ ៩៩ ) ។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មខេត្ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៨ វេលាម៉ោង ០៨ : ៣០នាទីព្រឹក។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ០៨ : ៣០ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៨ ។

បានពិនិត្យត្រឹមត្រូវ
អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

**អភិបាលខេត្ត និងជា**
**ប្រធានគណៈកម្មាធិការលទ្ធកម្មខេត្ត**

**ថោង សាវុន**

**ចម្លងជូន ៖**
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារ-កាលប្បវត្តិ